# អ្នកស្រី ឯម ផលាមុនី

អភិបាលរងខេត្តសៀមរាប

*ការមិនខ្លាចការងារធំ និងមិនរុញរាការងារតូចតាចនាំឲ្យអ្នកស្រីជោគជ័យក្នុងវិស័យនយោបាយ*

អ្នកស្រីឯម ផលាមុនីមានអាយុ៥៩ឆ្នាំ សព្វថ្ងៃមានតួនាទីជាអភិបាលរងខេត្តសៀមរាប។ លោកស្រីមានស្រុកកំណើតនៅ ភូមិត្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ដែលជាកន្លែងលោកស្រីរស់នៅបច្ចុប្បន្នផងដែរ។ ថ្មីៗនេះ លោកស្រីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែករដ្ឋបាលសាធារណៈ។ មុនឈានដល់តួនាទីដូចសព្វថ្ងៃ អ្នកស្រីបានបម្រើជាបុគ្គលិករដ្ឋបាលនៅសមាគមនារីខេត្តពីឆ្នាំ ១៩៨០ ដល់ឆ្នាំ១៩៩០។ ពីឆ្នាំ ១៩៩០ ដល់ឆ្នាំ ១៩៩៨ អ្នកស្រីជាបុគ្គលិកមន្ទីសមាគមនារីខេត្ត បន្ទាប់មក អ្នកស្រីមានតួនាទីជាអនុប្រធានមន្ទីកិច្ចការនារីខេត្ត ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៧ ។ អ្នកស្រីបានបម្រើតួនាទីជាអភិបាលរងខេត្តចាប់តាំងពីឆ្នាំ២០០៧ ដល់បច្ចុប្បន្ននេះ។



អ្នកស្រីយល់ថាមានកត្តាផ្ទាល់ខ្លួនមួយចំនួនដែលធ្វើឲ្យអ្នកស្រីជោគជ័យដូចសព្វថ្ងៃនេះ ទី១ អ្នកស្រីមានឆន្ទៈស្រួចស្រាល និងភាពប្រាកដនិយមក្នុងការងារ បើអ្នកស្រីចង់ធ្វើមួយ គឺគោរពធ្វើឲ្យបានសម្រេច ទោះបីជួបការលំបាកយ៉ាងណាក៏ដោយ។ ដោយចាប់ផ្តើមពីការហាត់រៀន កត់សំគាល់ និងធ្វើការងារតូចៗនៅជុំវិញខ្លួន ដូចជាការសំអាត ការយាមកាម ការរៀបចំកម្មវិធីផ្សេងៗនិង ការចូលរួមកម្មវិធីថ្នាក់ជាតិ ទើបធ្វើឲ្យអ្នកស្រីទទួលបានបទពិសោធន៍ច្រើនសម្រាប់ការងារ។ អ្នកស្រីយល់ថា ការមិនរុញរា និងមិនខ្លាចថោកទាបចំពោះការងារតូចក្តីធំក្តី ទើបបានជួយឲ្យការងារអ្នកស្រីមានលំនឹងល្អ។ ទី២ គឺទំនាក់ទំនងរវាងសហការីខាងក្រោមថ្នាក់ដឹកនាំខាងលើ ស្ថាប័នរដ្ឋាភិបាល និងកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិគឺជាកត្តាសំខាន់ ដែលជម្រុញឲ្យមានភាពជោគជ័យកាន់តែឆាប់រហ័ស ជាពិសេសធ្វើឲ្យអ្នកស្រីអាចរៀនពីកិច្ចការទាំងនេះថែមទៀត។ ម្យ៉ាងទៀត អ្នកស្រីជឿជាក់ថា ការរៀបចំអកប្បកិរិយាក៏ជាកត្តាសំខាន់ផងដែរ ព្រោះអកប្បកិរិយាក្នុងនយោបាយគឺជាការទាក់ទាញសណ្តានចិត្ត និងទទួលការគាំទ្រនិងភាពជឿជាក់ពីអ្នកជុំវិញខ្លួន និងប្រជាពលរដ្ឋ។ អកប្បកិរិយាទាំងនោះរួមមានការដើរហើរ ឈរ អង្គុយ និងការនិយាយស្តីដែលអ្នកស្រីបានហ្វឹកហាត់ ព្រោះប្រជាពលរដ្ឋ នឹងអង្កេតមើលគ្រប់អកប្បកិរិយារបស់អ្នកដឹកនាំ ព្រមទាំងគុណធម៌ និងសីលធម៌ក្នុងការរស់នៅ។ ក្រៅពីកត្តាផ្ទាល់ខ្លួន អ្នកស្រីបានទទួលជោគជ័យដោយសារមានការគាំទ្រ និងការលើកទឹកចិត្តពីក្រុមគ្រួសារ និងមិត្តភក្តិផងដែរ។

នៅថ្ងៃអនាគតអ្នកស្រ្តីនឹងបន្តការងារបម្រើរដ្ឋ  បើអ្នកស្រីនៅមានសុខភាពល្អ។  ទន្ទឹមនិងនោះអ្នកស្រី  នឹងបង្កើតមុខរបរមួយដែលអ្នកស្រីអាចធ្វើការបណ្ដើរ និងប្រកបមុខរបរបណ្ដើរ។

អត្ថបទរឿងរ៉ាវប្រវត្តិនេះអាចទាញយកបាននៅគេហទំព័រ www.cchrcambodia.org ជាខ្សែរអាត់សម្លេង និងវីដេអូខ្លី នៅក្នុង YouTube។

ផលិតដោយ៖


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

គម្រោងលើកស្ទួយសមាសភាពស្រ្តីក្នុងវិស័យនយោបាយនៅកម្ពុជា

ព័ត៌មានបន្ថែមសូមទាក់ទង៖

លេខទូរសព្ទ៖ ៨៥៥ ២៣ ៧២៦ ៩០១

អ៊ីមែល៖ info@cchrcambodia.org